ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១៣ ដោយអគ្គនាយកដ្ឋានពន្ធដារ

# កិច្ចប្រជុំស្តីអំពី
# សរុបលទ្ធផលការងារសារពើពន្ធប្រចាំខែ វិច្ឆិកា ឆ្នាំ២០១៣

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៣ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំ កិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាព របស់ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អមដោយឯកឧត្តម **ជូ វិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន អនុប្រធាននាយកដ្ឋាន លោកប្រធានសាខាពន្ធដារខណ្ឌទាំង៧នៅរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តទាំង២៣ទូទាំងប្រទេស។

ជាកិច្ចចាប់ផ្តើមឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសំដែងអំណរសាទរជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូល ពន្ធដារដែលសំរេចបានប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣ និងជម្រុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារសមាជិកអង្គប្រជុំ ដែលជាតំណាងមន្ត្រីពន្ធដារទូទាំងប្រទេសឲ្យខិតខំជំនះការលំបាកនិងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទឲ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែង និងអនុវត្តវិធានការនានាសំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៣។

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៣នេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ២២២,២៥៨ លានរៀល (គិតជាដុល្លារប្រមាណ ៥៥.៥លានដុល្លារ)។ បើប្រៀបធៀបទៅនឹងខែវិច្ឆិកាដូចគ្នាក្នុងឆ្នាំ២០១២ មានការកើនឡើងស្មើនិង ១១.៤%។ សរុបរយៈពេលដប់មួយខែក្នុងឆ្នាំ២០១៣ ចំណូលពន្ធអាករសរុបមានចំនួន ៣,២០០,៦៧៦ លានរៀល (គិតជាដុល្លារប្រមាណ ៨០០.២ លានដុល្លារ) ស្មើនឹង៩២.៤%នៃគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ក្នុងនោះថវិការដ្ឋសំរេចបានចំនួនស្មើនឹង ៨៩.៦% និងថវិការាជធានី-ខេត្តសម្រេចបានចំនួនស្មើនឹង ១១៣.៦%។ បើប្រៀបធៀបនឹងការអនុវត្តបានក្នុងរយៈពេលបដប់មួយខែដូចគ្នាក្នុងឆ្នាំ២០១២ ឃើញថាក្នុងឆ្នាំ២០១៣ នេះមានការកើនឡើងចំនួនស្មើនឹងអត្រាកំណើន ១៧,៣%។

តាមការវិភាគប្រភេទពន្ធឃើញថា ចំណូលក្នុងឆ្នាំ២០១៣ មានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងមានដូចជា ពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ២៦.៤% ពន្ធលើប្រាក់ចំណេញមានការកើនឡើងប្រមាណ ១៨.៣% អាករលើតម្លៃបន្ថែមមានការកើនឡើងប្រមាណ ១៩.៧% និង អាករពិសេសមានការកើនឡើងប្រមាណ ១៥.២% ។

ការពិនិត្យតាមវិស័យឃើញថា ចំណូលក្នុងឆ្នាំ២០១៣ មានការកើនឡើងស្ទើរគ្រប់សកម្មភាពក្នុងនោះ ផ្នែកផលិតភេសជ្ជៈកើនឡើងប្រមាណ២០.៤% ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២៧.៣% ផ្នែកទូរគមនាគមន៍កើនឡើងប្រមាណ ២៥.២% ផ្នែកផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ៣១.៦% ផ្នែកនីហរ័ណ-អាហារ័ណកើនឡើងប្រមាណ ១៩.៨% ស្ថាបត្យកម្មនិងសំណង់កើនឡើងប្រមាណ ២៨.១% ផ្នែកផលិតសម្លៀកបំពាក់ ៤៧.៣% ផ្នែកដឹកជញ្ជូននិងទេសចរណ៍ ៣៤.៥% អាកាសយានដ្ឋាននិងកំពង់ផែកើនឡើងប្រមាណ ៨០.៣% សណ្ឋាគារនិងផ្ទះសំណាក់កើនឡើងប្រមាណ ១៩.៥% លក់គ្រឿងយន្តស្មើនឹង

២៤២.៩% ផលិតម្ហូបអាហារស្មើនឹង ៤៨.៩៦ ផ្នែកផលិតគ្រឿងអេឡិចទ្រិចនិងអេឡិចត្រូនិច ស្មើនឹង ៤០.៣% និងផលិតផលគ្រឿងចករ ស្មើនឹង ៦២.៤%។

ក្នុងការពិភាក្សាអង្គប្រជុំបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា I-របាយការណ៍វឌ្ឍនភាពការងាររបស់នាយកដ្ឋាន សាខាពន្ធដារខេត្ត-ខណ្ឌ ស្តីពី ១-ការផ្ទេររបបម៉ៅការទៅរបបស្វ័យប្រកាស ២-ការធ្វើសវនកម្ម ៣-ការប្រមូលបំណុលពន្ធ II-សេចក្តីណែនាំអំពីការកំណត់ពន្ធចំពោះប្រាក់ខ្ចីគ្មានការប្រាក់ និងIII-បញ្ហាផ្សេងៗ។

ដើម្បីគ្រប់គ្រងចំណូលពន្ធដារឱ្យមានស្ថេរភាពលើវិស័យមួយចំនួន ដែលមានសក្តានុពលចំណូលច្រើន សម្រាប់ទិសដៅអនុវត្តបន្ត អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំនូវផែនការសកម្មភាពជាក់ស្តែងរបស់អគ្គនាយកដ្ឋានពន្ធដារ មានដូចខាងក្រោម៖

- ពង្រឹងអភិបាលកិច្ចរបស់មន្ត្រីពន្ធដារទាំងអស់ ដោយអប់រំមន្ត្រីឲ្យមានស្មារតីទទួលខុសត្រូវខ្ពស់ចំពោះការងារ ឲ្យផ្លាស់ប្តូររបៀបរបបនៃការធ្វើការងារព្រមទាំងដុសខាត់ លាង សម្អាត និងជម្រុះចោលរាល់ការប្រព្រឹត្តអំពើមិនគប្បីនានាដែលបានធ្វើកន្លងមក។
- គ្រប់គ្រងប្រសិទ្ធភាពម៉ោងការងាររបស់មន្ត្រី តាមរយៈការបំពាក់ឧបករណ៍ scan ម្រាមដៃ។
- រៀបចំប្រព័ន្ធលើកទឹកចិត្តមន្ត្រីពន្ធដារថែមមួយកម្រិតទៀត ដែលប្រព័ន្ធនៃការលើកទឹកចិត្តនេះ ត្រូវផ្អែកលើ អភិក្រមលទ្ធផលការងារ (Result-Based Approach) ជាមូលដ្ឋាន។
- បញ្ចូលអ្នកជាប់ពន្ធពីរបបម៉ៅការ ឲ្យទៅជាប់ពន្ធតាមរបបស្វ័យប្រកាសនូវអ្នកជាប់ពន្ធដែលមានផលរបរប្រចាំឆ្នាំដល់កម្រិតត្រូវជាប់ពន្ធតាមរបបស្វ័យប្រកាស។ ផែនការបញ្ចូលទៅរបបស្វ័យប្រកាសយ៉ាងតិច ២០% នៃចំនួនអ្នកជាប់ពន្ធតាមរបបម៉ៅការ នៅតាមសាខាពន្ធដារខេត្ត-ខណ្ឌនីមួយៗ។
- ពង្រឹងយន្តការត្រួតពិនិត្យ ដើម្បីពិនិត្យតាមដានការអនុវត្តផែនការទាំងនេះ និងដាក់ទោសទណ្ឌមន្ត្រីដែលលាក់ទុកមូលដ្ឋានពន្ធ ឬមិនព្រមផ្ទេរអ្នកជាប់ពន្ធពីរបបម៉ៅការទៅរបបស្វ័យប្រកាស។
- អនុវត្តយ៉ាងម៉ឺងម៉ាត់ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងប្រកបដោយភាពទន់ភ្លន់ នូវវិធានការតឹងទារបំណុលពន្ធ ដូចជា ឃាត់ទុកគណនីនៅធនាគារ,បញ្ឈប់ការនាំចេញនាំចូលទំនិញ, កាត់ទុកប្រាក់ពន្ធនៅរតនាគារជាតិ និងមិនអនុញ្ញាតឲ្យចូលដេញថ្លៃ មិនអនុញ្ញាតឲ្យផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ឬភាគហ៊ុន មិនអនុញ្ញាតចុះបញ្ជីបង្កើតក្រុមហ៊ុនថ្មី ផ្សាយឈ្មោះអ្នកជំពាក់បំណុលតាមសារព័ត៌មាន សហការជាមួយនគរបាលជាតិ និងប្តឹងទៅតុលាការ។
- ពិនិត្យជ្រើសរើសក្រុមហ៊ុនដែលប្រកាសខាតជាច្រើនឆ្នាំ ជាអាទិភាព ដើម្បីធ្វើសវនកម្មពេញលេញ។ ពង្រឹងការធ្វើសវនកម្ម ឬបង្កើនល្បឿនធ្វើសវនកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។
- ពង្រឹងការគ្រប់គ្រងប្រមូលអាករពិសេសលើទំនិញក្នុងស្រុកទាំងអស់ ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ តាមរយៈការរៀបចំយន្តការបិទសន្លឹកតែមប្រើ ដែលមានសុវត្ថិភាព និងសន្តិសុខជាងមុន លើទំនិញទាំងនោះ មុននឹងដាក់ឲ្យធ្វើចរាចរលើទីផ្សារក្នុងស្រុក។
- រៀបចំវគ្គបណ្តុះបណ្តាលមន្ត្រី ដោយអញ្ជើញគ្រូឧទ្ទេសនាមពីស្ថាប័នពាក់ព័ន្ធពីវិស័យឯកជន និងពីគ្រឹះស្ថាន អប់រំសិក្សាធិការ។
- ផ្សព្វផ្សាយដល់គ្រប់មជ្ឈដ្ឋាន នូវការមិនយកកម្រៃសេវាក្រៅផ្លូវការលើសេវានានារបស់អគ្គនាយកដ្ឋានពន្ធដារ។ អប់រំណែនាំមន្ត្រីរាជការពន្ធដារឲ្យគោរពវិជ្ជាជីវៈការងារ ក្រមសីលធម៌ ព្រមទាំងត្រូវរៀបចំកន្លែងសម្រាប់ទទួលជួបពិភាក្សាជាមួយអ្នកជាប់ពន្ធឲ្យបានសមរម្យ។
- រៀបចំបង្កើតការិយាល័យមជ្ឈមណ្ឌលផ្តល់ព័ត៌មាន (Call Center) និងការិយាល័យទំនាក់ទំនងសាធារណៈ ធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា ដោយរៀបចំជាប្រព័ន្ធ Data Base របស់អ្នកជាប់ពន្ធទៅតាមប្រភេទពន្ធ។

ជាកិច្ចបញ្ចប់ ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលដែលមានការកើនឡើងគួរជាទី ពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំបន្ថែមដល់ឯកឧត្តម អស់លោកជាថ្នាក់ដឹកនាំប្រធានអង្គភាពពន្ធដារគ្រប់

លំដាប់ថ្នាក់ និងមន្ត្រីពន្ធដារទាំងអស់ ខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសំរេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។







**អគ្គនាយកដ្ឋានពន្ធដារ**